**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការវាយតម្លៃការខូចខាតដែលបង្កឡើងដោយបាតុកម្មខុសច្បាប់ដឹកនាំដោយគណបក្សសង្គ្រោះជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៥ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១**.-

បង្កើតគណៈកម្មការមួយដើម្បីវាយតម្លៃការខូចខាត ដែលបង្កឡើងដោយបាតុកម្មខុសច្បាប់ដឹកនាំដោយគណបក្សសង្គ្រោះជាតិ ។



www.pheakdeylaw.com

**ប្រការ ២.-**

គណៈកម្មការនេះមានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- ឯកឧត្តម **លូ រ៉ាមីន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៤- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៦- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៧- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១១- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២- តំណាងសាលារាជធានីភ្នំពេញ និងសាលាខេត្តពាក់ព័ន្ធ | សមាជិក |

**ប្រការ ៣.-**

គណៈកម្មការនេះមានភារកិច្ច ដូចខាងក្រោម៖

- ចុះស្រាវជ្រាវព័ត៌មាន ចងក្រងឯកសារ និងប្រមូលវត្ថុតាងពាក់ព័ន្ធការប្រព្រឹត្តអំពើហិង្សា និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងឯកជន។
- ត្រួតពិនិត្យ និងបូកសរុបវាយតម្លៃអំពីទំហំនៃការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិលើគ្រប់វិស័យទាំងរបស់រដ្ឋ និងឯកជន ។
- រាយការណ៍ និងសុំយោបល់ផ្ទាល់ពី **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងពេលបំពេញភារកិច្ច ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងផ្តើមឡើងនូវវិធានការជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ ៤.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ និងប្រើប្រាស់មន្ត្រីក្រោមឱវាទជាជំនួយការ ។ សមាជិកគណៈកម្មការនេះត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានដែលទទួលសិទ្ធិពីប្រធាន ។



www.pheakdeylaw.com

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលរាជធានី-ខេត្ត និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារកាលប្បវត្តិ



www.pheakdeylaw.com